ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ១៩៥ សកបយ.

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០២

# ប្រកាស
## ស្តីពី
## ការហាមឃាត់ការជួលពលកម្មកុមារធ្វើការក្រោមដី

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

# សំរេច

ប្រការ១.- ក្មេងអាយុពី១៦ ឆ្នាំ ទៅក្រោម ១៨ ឆ្នាំ អាចប្រើអោយធ្វើការនៅអណ្តូងរ៉ែ ឬការយករ៉ែ ឬយកថ្មក្រោមដី បានតែក្នុងគោលបំណងហ្វឹកហ្វឺនវិជ្ជាជីវៈ និងជួយអោយក្មេងមានទម្លាប់ទៅនឹងមុខរបរនាពេលអនាគតរបស់ខ្លួនប៉ុណ្ណោះ ។ ការប្រើក្មេងក្នុងមុខរបរប្រភេទនេះ ត្រូវស្ថិតក្រោមល័ក្ខខ័ណ្ឌយ៉ាងតឹងរឹងដូចមានចែងក្នុងប្រការខាងក្រោម ។

ប្រការ២.- មុននឹងចូលធ្វើការ ក្មេងត្រូវទទួលការពិនិត្យកាយសម្បទាយ៉ាងម៉ត់ចត់ពីគ្រូពេទ្យការងារ រួមបញ្ចូលទាំងការថតសួតដោយវិទ្យុផង ។ ចំណាយលើការពិនិត្យកាយសម្បទាគឺជាបន្ទុករបស់និយោជក ។ វិញ្ញាបនប័ត្រកាយសម្បទា ដែលចេញដោយគ្រូពេទ្យការងារ ត្រូវរក្សាទុកដោយនិយោជក និងត្រូវបង្ហាញជូនអធិការការងារ ឬអធិការពេទ្យការងារតាមសំណើ ។ ការពិនិត្យកាយសម្បទានេះ ត្រូវធ្វើឡើងវិញរៀងរាល់រយៈពេល ៦ ខែ ។

ប្រការ៣.- និយោជកត្រូវមានសៀវភៅបញ្ជីសំរាប់ក្មេងដោយឡែកដែលក្នុងនោះត្រូវបញ្ជាក់ច្បាស់អំពី :-

-អាយុរបស់ក្មេង

-កាលបរិច្ឆេទ នៃការចុះក្រោមដីលើកទីមួយ

-ថិរវេលាសំរាកប្រចាំសប្តាហ៍

-ថិរវេលាសំរាកប្រចាំឆ្នាំ ។

ប្រការ៤.- មុននឹងចុះទៅធ្វើការក្រោមដី ក្មេងត្រូវទទួលការបណ្តុះបណ្តាលពិសេសដោយគ្រូស្ទាត់ជំនាញអំពី :-

-គ្រោះថ្នាក់ដែលអាចកើតមានចំពោះសុខភាព និងសន្តិសុខការងារនៅក្រោមដី

-ការសង្គ្រោះបន្ទាន់

-វិធានការការពារគ្រោះថ្នាក់ ការប្រើប្រាស់បរិក្ខាសុវត្ថិភាព និងសេចក្តីណែនាំអំពីសន្តិសុខការងារ ។

ប្រការ៥.- ក្មេងដែលធ្វើការក្រោមដី ត្រូវតែស្ថិតក្រោមការដឹកនាំរបស់គ្រូបង្ហាត់ដែលមានការទទួលខុសត្រូវខ្ពស់ ។ ក្នុងករណីនេះក្មេងអាចជួយការងារក្នុងក្រុម ដើម្បីអោយមានទម្លាប់ទៅនឹងមុខរបរនាពេលអនាគតរបស់ខ្លួន ប៉ុន្តែពេលវេលាហ្វឹកហ្វឺនពិតប្រាកដយ៉ាងហោចណាស់ក៏ត្រូវស្មើនឹងពាក់កណ្តាលនៃពេលវេលាធ្វើការទាំងអស់របស់ក្មេងនៅក្រោមដីដែរ ។

ប្រការ៦.- ក្មេងដែលធ្វើការក្រោមដីមិនត្រូវទុកអោយធ្វើការដោយគ្មានការឃ្លាំមើលឡើយ ។ ហាមឃាត់មិនអោយប្រើក្មេងកាន់ឧបករណ៍គ្រឿងយន្តណា ឬប្រើប្រាស់នូវរបៀបធ្វើអាជីវកម្មណាដែលអាចបណ្តាលអោយមានគ្រោះថ្នាក់ដល់ក្មេង ។

ប្រការ៧.- ក្មេងមិនអាចធ្វើការនៅក្រោមដីលើសពី ៤០ ម៉ោង ក្នុងមួយសប្តាហ៍ ឬ ៨ ម៉ោងក្នុងមួយថ្ងៃឡើយ ។

**ប្រការ៨.-** ក្មេងដែលធ្វើការក្រោមដី ត្រូវបានឈប់សំរាកប្រចាំសប្តាហ៍ដែលមានថិរវេលាយ៉ាងហោចណាស់ ៤៨ ម៉ោង ជាប់ គិតរួមបញ្ចូលទាំងថ្ងៃអាទិត្យ និងមានសិទ្ធិឈប់សំរាកប្រចាំឆ្នាំចំនួន ២៤ ថ្ងៃ បើបានធ្វើការជាប់ក្នុងមួយឆ្នាំ ទោះបីជាការធ្វើការនៅក្រោមដីមានលក្ខណៈមិនពេញពេលក៏ដោយ ។

**ប្រការ៩.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ២៩៧ សកអ.ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១០.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- -អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- -គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- -សមាគមនិយោជក
- -សហព័ន្ធសហជីព

"ដើម្បីជ្រាប"

- -គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- -រាជកិច្ច
- -កាលប្បវត្តិ និងឯកសារ